# ពិធីការសម្រាប់អាជីវកម្មលក់រាយ
# ការបើកដំណើរការសម្រាប់ការទិញទំនិញដោយផ្ទាល់៖ ឧបសម្ព័ន្ធ B

**បច្ចុប្បន្នភាពថ្មីៗ៖** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

**12/6/20៖**

- ដោយអនុលោមតាមសេចក្តីបង្គាប់ឲ្យស្ថិតនៅផ្ទះថ្នាក់តំបន់របស់រដ្ឋចេញនៅថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020 និងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2020 វេលាម៉ោង 11:59 អធ្រាត្រ (PST) រហូតដល់មានការជូនដំណឹងសារជាថ្មី មជ្ឈមណ្ឌលទិញទំនិញទាំងអស់ត្រូវតែ៖
    - ដាក់កម្រិតចំនួនមនុស្សត្រឹម 20% នៃចំនួនមនុស្សក្នុងអគារសរុប។ ចំនួនមនុស្សគឺផ្អែកលើច្បាប់សំណង់ (Building Code)។
    - អនុវត្តប្រព័ន្ធមួយសម្រាប់ការត្រួតពិនិត្យចំនួនមនុស្ស។
    - ហាមឃាត់អតិថិជនពីការបរិភោគអាហារ ឬភេសជ្ជៈនៅក្នុងអាជីវកម្ម។
    - បង្កើតម៉ោងពិសេសសម្រាប់ជនចាស់ជរា និងមនុស្សដទៃទៀតដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ ឬប្រព័ន្ធភាពស៊ាំចុះខ្សោយ។
- បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូច ដោយរាប់បញ្ចូលទាំងបន្ទប់តូចដែលមានរបាំងខណ្ឌចែក ត្រូវតែពាក់របាំងមុខ។ នេះគឺជាវិធានការណ៍បណ្តោះអាសន្នដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលបណ្តោះអាសន្ន ដែលបានចេញនៅថ្ងៃទី 28 ខែវិច្ឆិកា ឆ្នាំ 2020។ សេចក្តីតម្រូវនេះមានប្រសិទ្ធភាពចាប់ពីម៉ោង 12:01 អធ្រាត្រ (PST) ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2020 រហូតដល់មានការជូនដំណឹងសារជាថ្មី។
- នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគំលាត 6 ហ្វីតពីអ្នកដទៃ និងគួរធ្វើដូច្នោះនៅខាងក្រៅអគារ បើសិនជាអាចធ្វើបាន។ ការបរិភោគ ឬការផឹកនៅក្នុងបន្ទប់តូច ឬស្ថានីយការងារ គឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក។

**11/19/20៖** អាជីវកម្មលក់រាយដែលមិនចាំបាច់ទាំងអស់ ត្រូវតែបិទទ្វារសម្រាប់ប្រតិបត្តិការលក់រាយដោយផ្ទាល់ចាប់ពីម៉ោង 10:00 យប់ដល់ម៉ោង 5:00 ព្រឹក។ អាជីវកម្មលក់រាយអាចនឹងបន្តបើកសម្រាប់ការដឹកជញ្ជូន និងការទៅយកពីចិញ្ចើមថ្នល់ក្នុងអំឡុងម៉ោងដែលបានបិទសម្រាប់ប្រតិបត្តិការដោយផ្ទាល់។

នាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles កំពុងអនុវត្តវិធីសាស្ត្រតាមដំណាក់កាល ដែលបានគាំទ្រដោយវិទ្យាសាស្ត្រ និងជំនាញការសុខភាពសាធារណៈ ដើម្បីអនុញ្ញាតឲ្យអាជីវកម្មលក់រាយបើកទ្វារឡើងវិញដោយសុវត្ថិភាព។

អាជីវកម្មលក់រាយដែលមានហានិភ័យ (risk) ទាបលើកលែងតែអាជីវកម្មដែលបានកំណត់ថាចាំបាច់ ដោយអនុលោមតាមកឋាខណ្ឌទី 18 នៃសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលឲ្យនៅកន្លែងធ្វើការ និងនៅក្នុងសហគមន៍មានសុវត្ថិភាពជាងសម្រាប់ការបើកឡើងវិញដើម្បីគ្រប់គ្រងជំងឺ COVID-19 (សេចក្តីបង្គាប់) ត្រូវតែបិទទ្វារសម្រាប់ប្រតិបត្តិការលក់រាយដោយផ្ទាល់ ចាប់ពីម៉ោង 10:00 យប់ដល់ម៉ោង 5:00 ព្រឹក។ អាជីវកម្មលក់រាយអាចនឹងបន្តបើកសម្រាប់ការដឹកជញ្ជូន និងការទៅយកពីចិញ្ចើមថ្នល់ក្នុងអំឡុងម៉ោងដែលបានបិទសម្រាប់ប្រតិបត្តិការដោយផ្ទាល់។

អាជីវកម្មលក់រាយ ត្រូវបានដាក់កម្រិតចំនួនមនុស្សត្រឹម 20% នៃចំនួនមនុស្សអតិបរមាដោយអនុលោមតាមសេចក្តីបង្គាប់ឲ្យស្ថិតនៅផ្ទះថ្នាក់តំបន់របស់រដ្ឋ ចេញនៅថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020 និងមានប្រសិទ្ធភាពនៅថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2020 វេលាម៉ោង 11:59 អធ្រាត្រ (PST) រហូតដល់មានការជូនដំណឹងសារជាថ្មី។ ចំនួនមនុស្សគឺផ្អែកលើច្បាប់សំណង់ (Building Code)។

សូមកត់សម្គាល់៖ ឯកសារនេះអាចនឹងត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលមានព័ត៌មាន និងធនធានបន្ថែម ដូច្នេះសូមប្រាកដថាពិនិត្យមើលគេហទំព័រ LA County http://www.ph.lacounty.gov/media/Coronavirus/ ជាប្រចាំសម្រាប់បច្ចុប្បន្នភាពផ្សេងៗទៅលើឯកសារនេះ។

បញ្ជីត្រួតពិនិត្យនេះគ្របដណ្តប់៖

(1) គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក

(2) វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

(3) វិធានការណ៍ដើម្បីធានាបាននូវការគ្រប់គ្រងការឆ្លងជំងឺ

(4) ការទំនាក់ទំនងជាមួយបុគ្គលិក និងសាធារណៈជន

(5) វិធានការណ៍ដើម្បីធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព។

ចំណុចសំខាន់ៗទាំងប្រាំនេះត្រូវតែបានដោះស្រាយ នៅពេលដែលទីកន្លែងរបស់អ្នកបង្កើតពិធីការបើកឡើងវិញណាមួយ។

**អាជីវកម្មទាំងអស់ដែលស្ថិតក្រោមការណែនាំនេះ ត្រូវតែអនុវត្តវិធានការណ៍ជាធរមានទាំងអស់ ដែលមានរាយខាងក្រោមនេះ និងត្រូវត្រៀមខ្លួនពន្យល់ពីមូលហេតុក្នុងករណីដែលវិធានការណ៍ណាមួយ មិនត្រូវបានអនុវត្តដោយសារភាពមិនសមស្របសម្រាប់អាជីវកម្ម។**

**ឈ្មោះអាជីវកម្ម៖** ______________________

**អាសយដ្ឋានទីកន្លែង៖** ______________________

**ចំនួនមនុស្សអតិបរមាតាមច្បាប់សំណង់៖** ______________________

**កាលបរិច្ឆេទចុះផ្សាយ៖** ______________________

## A. គោលការណ៍ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពបុគ្គលិក (គូសធីកទាំងអស់ដែលអនុវត្តសម្រាប់ទីកន្លែង)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឲ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកងាយរងគ្រោះ (អ្នកដែលមានអាយុលើស 65 ឆ្នាំ ឬអ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃ) ត្រូវបានកំណត់ឲ្យធ្វើការងារដែលអាចធ្វើបានពីផ្ទះនៅគ្រប់ពេលដែលអាចធ្វើទៅបាន។
- ❑ បុគ្គលិកទាំងអស់ត្រូវបានប្រាប់ថាកុំមកធ្វើការ បើសិនជាឈឺ។ បុគ្គលិកយល់និងអនុវត្តតាមការណែនាំរបស់ DPH សម្រាប់ការដាក់ខ្លួនឲ្យនៅដាច់ដោយឡែក និងការនៅដាច់ពីគេ បើសិនជាអាចអនុវត្តបាន។ គោលការណ៍សុំច្បាប់ឈប់សម្រាកនៅកន្លែងធ្វើការ ត្រូវបានពិនិត្យឡើងវិញ និងបានកែប្រែដើម្បីធានាថាបុគ្គលិកមិនត្រូវបានពិន័យនៅពេលពួកគេស្ថិតនៅផ្ទះដោយសារជំងឺ។
- ❑ បុគ្គលិកបានទទួលព័ត៌មានអំពីអត្ថប្រយោជន៍នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលដែលបុគ្គលិកអាចនឹងមានសិទ្ធិទទួល ដែលនឹងធ្វើឲ្យវាកាន់តែមានភាពងាយស្រួលផ្នែកហិរញ្ញវត្ថុក្នុងការស្ថិតនៅផ្ទះ។ សូមមើលព័ត៌មានបន្ថែមស្តីពី កម្មវិធីរដ្ឋាភិបាលដែលគាំទ្រ ការឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 ដោយរាប់បញ្ចូលទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិកក្រោម ច្បាប់ស្តីពីការឆ្លើយតបនឹងមេរោគកូរ៉ូណា ដោយយកគ្រួសារជាអាទិភាព (Families First Coronavirus Response Act) និងសិទ្ធិរបស់បុគ្គលិកដើម្បីទទួល អត្ថប្រយោជន៍សំណងបុគ្គលិក និងការសន្និដ្ឋានភាពទាក់ទងនឹងការងារនៃការប៉ះពាល់ជាមួយជំងឺ COVID-19 ដែលកើតឡើងចន្លោះថ្ងៃទី 19 ខែមីនា និងថ្ងៃទី 5 ខែកក្កដាដោយអនុលោមតាម បទបញ្ញាប្រតិបត្តិលេខ N-62-20 របស់អភិបាលរដ្ឋ។
- ❑ ដំណើរការការងារត្រូវបានកែទម្រង់ឡើងវិញទៅតាមកម្រិតដែលអាចធ្វើបាន ដើម្បីបង្កើនឱកាសសម្រាប់ឲ្យបុគ្គលិក

ធ្វើការងារពីផ្ទះបាន។

- ❑ បន្ទាប់ពីទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ធ្វើតេស្តវិជ្ជមាន ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកមានគម្រោង ឬពិធីការដើម្បីឲ្យករណីទាំងនោះដាក់ខ្លួនឲ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឲ្យដាក់ខ្លួនឲ្យនៅដាច់ពីគេភ្លាមៗសម្រាប់បុគ្គលិកដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការ។ គម្រោងរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលបាននៅដាច់ពីគេទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀត ឬទេ ដែលអាចតម្រូវឲ្យមានវិធានការគ្រប់គ្រងជំងឺ COVID-19 បន្ថែម។ សូមមើលការណែនាំសុខភាពសាធារណៈស្តីពី ការឆ្លើយតបនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។
- ❑ ការត្រួតពិនិត្យបុគ្គលិក ត្រូវបានធ្វើឡើងមុនពេលបុគ្គលិកអាចចូលក្នុងកន្លែងធ្វើការ។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬទេ។ ការពិនិត្យទាំងនេះអាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់បន្ទាប់ពីបុគ្គលិកមកដល់។ ការពិនិត្យសីតុណ្ហភាពក៏គួរតែធ្វើឡើងនៅកន្លែងធ្វើការផងដែរ បើសិនជាអាចធ្វើបាន។
- ❑ នៅក្នុងករណីដែលរកឃើញមាន 3 ករណី ឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជកត្រូវតែរាយការណ៍ពីចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈ នឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាចង្កោម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ជំនួយបច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈ នឹងត្រូវបានចាត់តាំង ដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាចង្កោមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។
- ❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃបានទទួលរបាំងមុខសមស្របដែលគ្របច្រមុះ និងមាត់ដោយឥតគិតថ្លៃ។ បុគ្គលិកត្រូវពាក់របាំងមុខគ្រប់ពេលវេលា ក្នុងអំឡុងថ្ងៃធ្វើការ នៅពេលប៉ះពាល់ ឬទំនងជាប៉ះពាល់ជាមួយអ្នកដទៃ។ បុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនថាពួកគេមិនគួរពាក់របាំងមុខ គួរពាក់សន្ទះបាំងមុខដែលមានក្រណាត់គ្របនៅគែមខាងក្រោម ដើម្បីអនុលោមតាមបទបញ្ជារបស់រដ្ឋ ដរាបណាល័ក្ខខ័ណ្ឌសុខភាពរបស់ពួកគេអនុញ្ញាត។ យកល្អគួរប្រើក្រណាត់គ្របដែលមានទម្រង់រឹតតឹងនៅខាងក្រោមចង្កា។ ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវគឺមិនគួរប្រើឡើយ។ បុគ្គលិកមិនចាំបាច់ពាក់ក្រណាត់បាំងមុខពេលនៅម្នាក់ឯងនៅក្នុងការិយាល័យឯកជន ឬបន្ទប់តូចដែលមានរបាំងរឹងការពារខ្ពស់ជាងកម្ពស់បុគ្គលិកនៅពេលឈរនោះទេ។
- ❑ ដោយអនុលោមតាមសេចក្តីបង្គាប់របស់មន្ត្រីសុខាភិបាលដើម្បីគ្រប់គ្រងជំងឺ COVID-19៖ ការឆ្លើយតបនឹងការកើនឡើងខ្លាំងលំដាប់ថ្នាក់ទី 1 បានចេញនៅថ្ងៃទី 28 ខែវិច្ឆិកា ឆ្នាំ 2020 បុគ្គលិកទាំងអស់ត្រូវតែពាក់របាំងមុខនៅគ្រប់ពេលវេលា លើកលែងតែពេលធ្វើការម្នាក់ឯងនៅក្នុងការិយាល័យឯកជនដោយបិទទ្វារជិត ឬនៅពេលបរិភោគ ឬផឹក។ ករណីលើកលែងដែលមានសម្រាប់បុគ្គលិកដែលធ្វើការនៅក្នុងបន្ទប់តូចដោយមានរបាំងខ័ណ្ឌរឹងមាំហួសពីកម្ពស់របស់បុគ្គលិក ពេលនេះ ត្រូវបានដកចោលដែលមានប្រសិទ្ធភាពក្នុងសេចក្តីបង្គាប់បណ្តោះអាសន្ននេះ ពោលគឺចាប់ពីម៉ោង 12:01 អធ្រាត្រ (PST) ថ្ងៃទី 30 ខែវិច្ឆិកា ឆ្នាំ 2020 រហូតដល់មានការជូនដំណឹងសារជាថ្មី។
- ❑ ដើម្បីធ្វើឲ្យប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួន និងត្រឹមត្រូវ បុគ្គលិកត្រូវបានរារាំងមិនឲ្យបរិភោគ ឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួន និងរក្សាគំលាតរវាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគំលាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក គួរតែធ្វើនៅខាងក្រៅអគារ និងឆ្ងាយពីអ្នកដទៃបើសិនជាអាចធ្វើបាន។ ការបរិភោគ ឬការផឹកនៅបន្ទប់តូច ឬស្ថានីយការងារគឺប្រសើរជាងការបរិភោគនៅក្នុងបន្ទប់សម្រាក បើសិនជាការបរិភោគនៅបន្ទប់តូច ឬស្ថានីយការងារផ្តល់ជូនគំលាតកាន់តែធំ និងរបាំងរវាងបុគ្គលិក។

- [ ] ចំនួនមនុស្សត្រូវបានកាត់បន្ថយ ហើយគំលាតរវាងបុគ្គលិក ត្រូវបានបង្កើនជាអតិបរមានៅក្នុងបន្ទប់ ឬកន្លែងនានាដែលបុគ្គលិកប្រើសម្រាប់បរិភោគអាហារនិង/ឬសម្រាក។ ចំណុចនេះត្រូវបានសម្រេចដោយៈ
    - [ ] កំណត់ចំនួនមនុស្សអតិបរមាដែលអនុញ្ញាតឲ្យមានការរក្សាគំលាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើសម្រាប់ការសម្រាក
    - [ ] ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក ព្រមទាំង
    - [ ] ដាក់តុឃ្លាតពីគ្នាប្រាំមួយហ្វីត និងធានាបាននូវគំលាតប្រាំមួយហ្វីតរវាងកន្លែងអង្គុយ ដោយដកកៅអី ឬបិទបង់ស្អិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសម្គាល់លើកម្រាលឥដ្ឋ ដើម្បីធានាបាននូវការរក្សាគំលាត និងរៀបចំកន្លែងអង្គុយ តាមរបៀបដែលអាចកាត់បន្ថយ ការប៉ះពាល់ទល់មុខគ្នា។ ការប្រើប្រាស់របាំងខណ្ឌចែក ត្រូវបានលើកទឹកចិត្ត ដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួស ឲ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគំលាតរាងកាយឡើយ។
- [ ] បុគ្គលិកត្រូវបានណែនាំឲ្យបោកគក់ឬផ្លាស់ប្ដូររបាំងមុខរបស់ខ្លួនជារៀងរាល់ថ្ងៃ។
- [ ] និយោជកគួរពិចារណាពីកន្លែងដែលការប្រើប្រាស់ស្រោមដៃប្រើហើយអាចបោះចោលបាន អាចមានប្រយោជន៍ដើម្បីបំពេញបន្ថែមលើការលាងដៃញឹកញាប់ ឬប្រើប្រាស់ទឹកអនាម័យលាងដៃ។ ឧទាហរណ៍គឺសម្រាប់ឲ្យបុគ្គលិកដែលកំពុងពិនិត្យអ្នកដទៃរករោគសញ្ញា ឬកំពុងចាត់ចែងវត្ថុដែលបានប៉ះពាល់ជាទូទៅ។
- [ ] ស្ថានីយការងារទាំងអស់ត្រូវបានបំបែកពីគ្នាយ៉ាងតិចប្រាំមួយហ្វីត។
- [ ] ទីកន្លែងចែកចាយ (សម្រាប់ការយកអីវ៉ាន់ពីចិញ្ចើមថ្នល់) បន្ទប់សម្រាក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានសម្លាប់មេរោគជារៀងរាល់ម៉ោងទៅតាមកាលវិភាគដូចខាងក្រោមៈ
    - កន្លែងចែកចាយ ________________________________
    - បន្ទប់សម្រាក ________________________________
    - បន្ទប់ទឹក ________________________________
    - ផ្សេងទៀត ________________________________
- [ ] ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីប្រាក់ឈ្នួល និងម៉ោងធ្វើការ ការសម្រាកត្រូវបានកំណត់ដាច់ៗពីគ្នា ដើម្បីប្រាកដថាបុគ្គលិកអាចរក្សាគំលាតប្រាំមួយ (6) ហ្វីតពីគ្នានៅក្នុងបន្ទប់សម្រាកនៅគ្រប់ពេលវេលា។
- [ ] សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកនៅទីតាំងដូចខាងក្រោមៈ

  ______________________________________________________________
- [ ] ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់ នៅទីតាំងដូចខាងក្រោមៈ

  ______________________________________________________________
- [ ] បុគ្គលិកត្រូវបានអនុញ្ញាតឲ្យសម្រាកដើម្បីលាងដៃរបស់ខ្លួន។
- [ ] ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកនីមួយៗ។
- [ ] ទៅតាមកម្រិតដែលអាចធ្វើបាន កម្មករនីមួយៗ ត្រូវបានកំណត់ឧបករណ៍ផ្ទាល់ខ្លួន បរិក្ខារ និងកន្លែងធ្វើការដែលបានកំណត់។ ការប្រើប្រាស់រួមគ្នានូវវត្ថុដែលបានប៉ះរួច ត្រូវបានកាត់បន្ថយ ឬលុបបំបាត់។
- [ ] បុគ្គលិកទទួលបានពេលវេលាក្នុងអំឡុងវេនធ្វើការរបស់ខ្លួន ដើម្បីអនុវត្តការសម្អាត។ កិច្ចការសម្អាតគួរត្រូវបានកំណត់ក្នុងអំឡុងម៉ោងធ្វើការ ជាផ្នែកមួយនៃភារកិច្ចការងាររបស់បុគ្គលិក។
- [ ] គោលការណ៍ទាំងអស់ដែលបានពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះក្រៅពីគោលការណ៍ដែលទាក់ទងនឹងលក្ខខណ្ឌការងារ ត្រូវបានអនុវត្តទៅលើបុគ្គលិកដឹកជញ្ជូន និងក្រុមហ៊ុនផ្សេងៗទៀតដែលអាចស្ថិតនៅទីតាំងនោះក្នុងនាមជាភាគីទីបី។

❑ ស្រេចចិត្ត—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

______________________________________________________________________________

## B. វិធានការណ៍ដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ

❑ ចំនួនអតិថិជននៅក្នុងហាងលក់រាយក្នុងអគារ និងហាងនីមួយៗមានកម្រិតទាបល្មមដើម្បីធានាបាននូវការរក្សាគំលាតរាងកាយ ប៉ុន្តែមិនថាក្នុងករណីណា គឺមិនឲ្យលើសពី 20% នៃចំណុះផ្ទុកអតិបរមានៃចំណុះហាងលក់រាយ។

ចំនួនអតិថិជនអតិបរមានៅក្នុងទីកន្លែងត្រូវបានដាក់កម្រិតត្រឹម៖ ____________________________

❑ ហាងលក់រាយត្រួតពិនិត្យច្រកចូលទាំងអស់ដើម្បីតាមដានចំនួនអតិថិជន។ នៅពេលដែលអាចធ្វើបាន ផ្តល់ច្រកចូលតែមួយដែលបានកំណត់ច្បាស់លាស់ និងច្រកចេញដាច់ដោយឡែកដើម្បីជួយអនុវត្តក្នុងការរក្សាគំលាតរាងកាយ។

❑ ត្រៀមរៀបចំឲ្យអតិថិជនតម្រង់ជួរនៅខាងក្រៅ ខណៈដែលនៅតែអនុវត្តការរក្សាគំលាតរាងកាយ រាប់បញ្ចូលទាំងការប្រើប្រាស់តម្រុយជារូបភាព។ បើសិនជាចាំបាច់ បុគ្គលិកម្នាក់ (ឬច្រើននាក់បើសិនជាមានច្រកចូលច្រើនជាងមួយ) ដែលពាក់ក្រណាត់បាំងមុខអាចត្រូវបានដាក់ឲ្យប្រចាំការនៅជិតទ្វារ ប៉ុន្តែមានគំលាតយ៉ាងតិច 6 ហ្វីតពីអតិថិជនដែលជិតបំផុត ដើម្បីតាមដានចំនួនអតិថិជន និងដើម្បីណែនាំឲ្យអតិថិជនតម្រង់ជួរដោយឃ្លាតពីគ្នាប្រាំមួយហ្វីតនៅខាងក្រៅច្រកចូល បើសិនជាអាជីវកម្មបានឈានដល់ដែនកំណត់ចំនួនអតិថិជនរបស់ខ្លួន។

❑ វិធានការត្រូវបានអនុវត្តដើម្បីធានាបាននូវការរក្សាគំលាតរាងកាយយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលិក និងអតិថិជន។ នេះអាចរាប់បញ្ចូលការប្រើប្រាស់ការបែងចែកជាក់ស្តែង ឬតម្រុយជារូបភាព (ឧ. ការសម្គាល់លើកម្រាលឥដ្ឋ បង់ស្អិតមានពណ៌ ឬសញ្ញាដើម្បីចង្អុលបង្ហាញពីកន្លែងដែលកម្មករ និង/ឬនិយោជិតគួរឈរ។)

❑ ផ្តល់ច្រកចូលតែមួយដែលបានកំណត់ច្បាស់លាស់ និងច្រកចេញដាច់ដោយឡែកដើម្បីជួយអនុវត្តការរក្សាគំលាតរាងកាយ នៅពេលដែលអាចធ្វើបាន។

❑ បានចាត់វិធានការណ៍នៅកន្លែងគិតលុយដើម្បីកាត់បន្ថយការប៉ះពាល់រវាងអ្នកគិតលុយ និងអតិថិជន ដូចជារបាំងកញ្ចក់ Plexiglas។ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅជិតច្រកចូល ផ្លូវចេញគិតលុយ និងបញ្ជរដើម្បីរំលឹកដល់អតិថិជនអំពីការរក្សាគំលាតរាងកាយ។

❑ បង់ស្អិត ឬការសម្គាល់ផ្សេងទៀតបញ្ជាក់ពីកន្លែងចាប់ផ្តើមសម្រាប់អតិថិជនចូលក្នុងជួរគិតលុយ និងគំលាត 6 ហ្វីតសម្រាប់អតិថិជនដែលមកក្រោយៗទៀត ដែលចូលតម្រង់ជួរ។

❑ បុគ្គលិកត្រូវបានណែនាំឲ្យរក្សាគំលាតយ៉ាងតិចប្រាំមួយ (6) ហ្វីតពីអតិថិជន និងពីបុគ្គលិកដូចគ្នានៅគ្រប់កន្លែងទាំងអស់នៃហាង។ បុគ្គលិកអាចមកជិតជាបណ្តោះអាសន្ន នៅពេលចាំបាច់ដើម្បីទទួលយកការបង់ប្រាក់ បញ្ជូនទំនិញឬសេវាកម្ម ឬទៅតាមការចាំបាច់។

❑ បន្ទប់ទឹកបុគ្គលិក មិនអាចឲ្យអតិថិជនប្រើបានទេ។

❑ ស្ថានីយការងាររបស់បុគ្គលិក ត្រូវបានបំបែកពីគ្នាយ៉ាងតិច 6 ហ្វីត ហើយទីកន្លែងទូទៅត្រូវបានកំណត់ឲ្យដាក់កម្រិតលើការប្រមូលផ្តុំរបស់បុគ្គលិក ដើម្បីធានាបាននូវការរក្សាគំលាតពិតយ៉ាងតិច 6 ហ្វីត។

❑ បន្ទប់សម្រាក និងទីកន្លែងទូទៅផ្សេងទៀត ត្រូវបានកំណត់ឲ្យដាក់កម្រិតលើការប្រមូលផ្តុំរបស់បុគ្គលិក ដើម្បីធានាបាននូវការរក្សាគំលាតពិតយ៉ាងតិច 6 ហ្វីត។ នៅពេលដែលអាចធ្វើបាន ទីកន្លែងសម្រាកនៅខាងក្រៅអគារដែលមានម្លប់ជ្រក និងកន្លែងអង្គុយ ត្រូវបានបង្កើតឡើងដើម្បីជួយធានាបាននូវការរក្សាគំលាតរាងកាយ។ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីប្រាក់ឈ្នួល និងម៉ោងធ្វើការ ការសម្រាករបស់បុគ្គលិកត្រូវបានធ្វើឡើងដាច់ៗពីគ្នាដើម្បីជួយរក្សាការអនុវត្តពិធីការនៃការរក្សាគំលាតរាងកាយ។

❑ សេចក្តីតម្រូវនៃការរក្សាគំលាតរាងកាយត្រូវបានអនុវត្តនៅកន្លែងលើកឥវ៉ាន់ (loading bay) ហើយចុះហត្ថលេខា

ដោយមិនប៉ះត្រូវបានអនុវត្តសម្រាប់ការដឹកជញ្ជូន។

- ❑ អ្នកបើកឡានដឹកទំនិញដែលមិនមែនជាបុគ្គលិក ភ្នាក់ងារដឹកជញ្ជូន ឬអ្នកលក់ដែលតម្រូវឲ្យចូលក្នុងទីតាំងលក់រាយ ត្រូវពាក់ក្រណាត់បាំងមុខ។

## C. វិធានការណ៍ដើម្បីគ្រប់គ្រងការឆ្លងជំងឺ

- ❑ ប្រព័ន្ធ HVAC គឺស្ថិតក្នុងសភាពដំណើរការធម្មតា ដើម្បីបង្កើនកម្រិតជាអតិបរមា ខ្យល់ចេញចូលត្រូវបានបង្កើន។ ពិចារណាដំឡើងម៉ាស៊ីនសម្អាតខ្យល់មានប្រសិទ្ធភាពខ្ពស់ចល័ត ធ្វើឲ្យប្រសើរឡើងនូវតម្រងខ្យល់របស់អគារឲ្យមានប្រសិទ្ធភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅ និងខ្យល់ចេញចូលនៅក្នុងការិយាល័យ និងទីកន្លែងផ្សេងៗទៀត។
- ❑ ប្រព័ន្ធបង់ប្រាក់ដោយមិនបាច់ប៉ះ គឺមានសម្រាប់ឲ្យប្រើ ឬបើមិនអាចធ្វើបាន ប្រព័ន្ធបង់ប្រាក់ត្រូវបានធ្វើអនាម័យជាប្រចាំ។ ពិពណ៌នា៖

________________________________________________________________

- ❑ ទីកន្លែងទូទៅ និងវត្ថុដែលបានប៉ះញឹកញាប់នៅកន្លែងយកទំនិញរបស់អតិថិជន និងកន្លែងបង់ប្រាក់ (ឧ. តុ ដៃទ្វារ ម៉ាស៊ីនអានកាតឥណទាន) ត្រូវបានសម្លាប់មេរោគរៀងរាល់ម៉ោងក្នុងអំឡុងម៉ោងធ្វើការ ដោយប្រើសារធាតុសម្លាប់មេរោគដែលបានអនុញ្ញាតដោយ EPA។
- ❑ ទីកន្លែងការងារ និងអគារទាំងមូលត្រូវបានសម្អាតយ៉ាងហោចណាស់រាល់ថ្ងៃ ហើយបន្ទប់ទឹក និងតំបន់/វត្ថុដែលបានប៉ះញឹកញាប់ ត្រូវបានសម្អាតជារៀងរាល់ម៉ោង។
- ❑ ម៉ោងហាងលក់រាយត្រូវបានកែសម្រួល ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការសម្អាតស៊ីជម្រៅជាប្រចាំ និងការដាក់ស្តុកផលិតផល។ កំណត់ពេលរៀបស្តុកទំនិញដាច់ៗពីគ្នាដើម្បីឲ្យបុគ្គលិកស្ថិតនៅក្នុងរបៀងខុសៗគ្នា។
- ❑ នៅពេលដែលអាចធ្វើបាន ចូរលើកទឹកចិត្តឲ្យអតិថិជនប្រើប្រាស់កាតឥណពន្ធ ឬឥណទាន លើកទឹកចិត្តឲ្យអតិថិជនសម្អាតថង់ដែលអាចប្រើប្រាស់ឡើងវិញជាញឹកញាប់ និងតម្រូវឲ្យអតិថិជនយកថង់ដែលអាចប្រើប្រាស់ឡើងវិញដើម្បីដាក់ទំនិញដែលបានទិញរបស់ខ្លួន។
- ❑ បន្ទប់លសំលៀកបំពាក់ដែលបើកឲ្យអតិថិជនប្រើប្រាស់ ត្រូវបានត្រួតពិនិត្យដោយបុគ្គលិក។ សំលៀកបំពាក់ទាំងឡាយណាដែលត្រូវបានល ប៉ុន្តែមិនបានទិញត្រូវបានដាក់ដោយឡែករយៈពេល 24 ម៉ោងមុននឹងត្រឡប់ទៅស្ទួរ ឬផ្ញើរវិញ។
- ❑ ភ្ញៀវដែលមកដល់អាជីវកម្មត្រូវបានរំលឹកឲ្យពាក់របាំងមុខនៅគ្រប់ពេលវេលា ខណៈពេលនៅក្នុងអាជីវកម្ម ឬលើទីធ្លារបស់អាជីវកម្ម។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ មានតែបុគ្គលដែលត្រូវបានណែនាំមិនឲ្យពាក់របាំងមុខដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ខ្លួនប៉ុណ្ណោះ ទើបត្រូវបានលើកលែងពីការពាក់ម៉ាស។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិកអ្នក និងភ្ញៀវផ្សេងទៀត គួរផ្តល់របាំងមុខដល់ភ្ញៀវដែលមកដល់ដោយមិនមានម៉ាស។
- ❑ ការពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលភ្ញៀវអាចចូលក្នុងទីកន្លែង។ ការពិនិត្យត្រូវតែរាប់បញ្ចូលការពិនិត្យពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម គ្រុនក្តៅឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឲ្យនៅដាច់ដោយឡែក ឬឲ្យនៅដាច់ពីគេនាពេលបច្ចុប្បន្នឬក៏អត់។ ការត្រួតពិនិត្យទាំងនេះអាចធ្វើបានដោយផ្ទាល់ ឬតាមរយៈវិធីផ្សេងដូចជាប្រព័ន្ធចុះឈ្មោះតាមអនឡាញ ឬតាមរយៈស្លាកសញ្ញាដែលបានបិទនៅច្រកចូលទីកន្លែងដោយថ្លែងថាភ្ញៀវដែលមានរោគសញ្ញាទាំងនេះមិនគួរចូលក្នុងទីកន្លែងឡើយ។
- ❑ អតិថិជនដែលមកដល់ទីកន្លែងជាមួយក្មេងៗ ត្រូវប្រាកដថាកូនរបស់ពួកគេស្ថិតនៅជិតឪពុកម្តាយ ចៀសវាងការប៉ះអ្នកដទៃ ឬវត្ថុណាមួយដែលមិនមែនជារបស់ពួកគេ និងត្រូវពាក់ម៉ាស់បើសិនជាដល់អាយុ។
- ❑ បារនៅក្នុងហាង ជម្រើសទិញផលិតផលដោយថ្លឹងទម្ងន់ (bulk-bin) និងការសាកផលិតផលត្រូវបានបញ្ឈប់។
- ❑ ទំនិញដែលបានទិញត្រូវបានប្រគល់ឲ្យអតិថិជនក្នុងកញ្ចប់ ឬថង់បិទជិតដោយមានវិក្កយបត្រភ្ជាប់ជាមួយ។

- ❑ អតិថិជនត្រូវបានរំលឹកថាពួកគេមិនត្រូវបានអនុញ្ញាតឲ្យបរិភោគ ឬផឹកខណៈពេលនៅក្នុងអាជីវកម្មលក់រាយឡើយ។
- ❑ នៅពេលដែលអាចធ្វើបាន ឧបករណ៍ដែលមិនប្រើដៃដូចជាអំពូលភ្លើងសិនស័រចលនា ប្រព័ន្ធបង់ប្រាក់ដោយមិនបាច់ប៉ះ ឧបករណ៍បាញ់សាប៊ូនិងបញ្ចេញក្រដាសជូតស្វ័យប្រវត្តិ និងប្រព័ន្ធកាតពេលវេលា ត្រូវបានដំឡើង។
- ❑ ទឹកអនាម័យលាងដៃ ក្រដាសជូតមាត់ និងធុងសម្រាមគឺមានសម្រាប់សាធារណៈជននៅ ឬជិតច្រកចូលទីកន្លែង។
- ❑ ការសម្លាប់មេរោគឧបករណ៍សម្រាប់បង់ប្រាក់ ប៊ិច ប៊ិចសម្រាប់ប្រើលើអេក្រង់រៀងរាល់ម៉ោង។

ស្រេចចិត្ត - ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត (ឧ. ការផ្តល់ម៉ោងធ្វើការសម្រាប់តែជនចាស់ជរា ផ្តល់ការលើកទឹកចិត្តសម្រាប់ការលក់នៅក្រៅម៉ោងរវល់ខ្លាំង)៖

______________________________________________________________________

## D. វិធានការណ៍ដែលទំនាក់ទំនងជាមួយសាធារណៈជន

- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងអគារ។
- ❑ ការបិទផ្សាយនៅច្រកចូល និង/ឬនៅកន្លែងដែលអតិថិជនតម្រង់ជួរជូនដំណឹងដល់អតិថិជនពីជម្រើស និងគុណសម្បត្តិនៃការបញ្ជាទិញជាមុន និងបង់ប្រាក់ជាមុន។
- ❑ ស្លាកសញ្ញានៅក្នុងអាជីវកម្មទាំងមូល ដែលរំលឹកដល់អតិថិជនថា មិនអនុញ្ញាតឲ្យមានការបរិភោគ ឬការផឹកនៅខាងក្នុងឡើយ។
- ❑ ច្រកអនឡាញរបស់អាជីវកម្ម (គេហទំព័រ បណ្តាញសង្គម ។ល។) ផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងបើកហាង ការតម្រូវឲ្យប្រើរបាំងមុខ គោលការណ៍ទាក់ទងនឹងការបញ្ជាទិញជាមុន ការបង់ប្រាក់ជាមុន ការមកយកទំនិញនិង/ឬការដឹកជញ្ជូន និងបញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព

- ❑ បើសិនជាសមស្រប ម៉ោងទិញឥវ៉ាន់ដាច់ដោយឡែកសម្រាប់ប្រជាជនងាយរងគ្រោះ ដូចជាជនចាស់ជរា និងអ្នកដែលងាយរងគ្រោះតាមបែបវេជ្ជសាស្ត្រត្រូវបានចាប់ផ្តើម យកល្អបន្ទាប់ពីសម្អាតរួច។
- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់អតិថិជន ត្រូវបានផ្តល់អាទិភាព។
- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អតិថិជនដែលមានការលំបាកក្នុងការផ្លាស់ទី និង/ឬដែលមានហានិភ័យខ្ពស់នៅទីសាធារណៈ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ដែលអាជីវកម្មគួរភ្ជាប់ជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងអាជីវកម្ម៖** ______________________________

**លេខទូរស័ព្ទ៖** ______________________________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ______________________________